សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: ៥១០ "ខ"

ចុះថ្ងៃទី ១៧-០២-២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៨០៤

ចុះថ្ងៃទី ៣១-១២-២០២១

-សំណុំរឿងស៊ើបសួរលេខ:១៣៤៦

ចុះថ្ងៃទី ១៣-៤-២០២២

-សំណុំរឿងជំនុំជម្រះលេខ:៤៦៣៤

ចុះថ្ងៃទី ០៨-១២-២០២២

ឱព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ១៤និង ៣០នាទី នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៥៨០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មានជនជាប់ចោទ:

ឈ្មោះ [redacted]កុសល ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានសាលាដំបូងខេត្តព្រះសីហនុ កំរិតវប្បធម៌ បរិញ្ញាប័ត្រ ទីកន្លែងកំនើតនៅ [redacted] សាសនា ព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៣ ផ្លូវលេខ៧ ភូមិ១ សង្កាត់០១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted]**សុភាន់** (រ) ម្តាយឈ្មោះ[redacted]**ភា** (រ) ជានីតិជន ទាសពីមុន គ្មាន ។

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យជាប់កាតព្វកិច្ចតាមផ្លូវតុលាការ លេខ **៥៨៤៦** (គ១) **ដ.ស.ព** ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជាប់ចោទពីបទ **ឆបោក** ប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីឆ្នាំ២០២១ បទល្មើស ព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាក់ ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិខ្នារ សង្កាត់ជ្រោរ ក្រុងសៀមរាប ខេត្តសៀមរាប ។

មានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែមីនា ឆ្នាំ២០២១ ឈ្មោះ[redacted] REN GUI ជនជាតិចិន បានលួចសម្ភារៈជាច្រើននៅក្នុងអគារក្រុមហ៊ុនរបស់ឈ្មោះ [redacted] សាក់ ហើយបានរត់គេចខ្លួនបាត់រហូតមកដល់ពេលនេះធ្វើឱ្យក្រុមហ៊ុនមានការខូចខាតបង់ទ្រព្យសម្បត្តិជាច្រើន។ បន្ទាប់មកឈ្មោះ [redacted] សាក់ បានផ្ទេរការងារមកឱ្យឈ្មោះ [redacted] តាយស៊ឹង

ដែលមានអ្នកបកប្រែឈ្មោះ [redacted] សុភ័ក្រ ក្នុងការដាក់ពាក្យបណ្តឹងទៅលើឈ្មោះ [redacted] REN GUI នៅសាលាដំបូងខេត្តព្រះសីហនុ ។ នៅពេលទៅដល់ក៏បានជួបនឹងឈ្មោះ [redacted] កុសល ហើយឈ្មោះនេះបានធានាអះអាងប្រាប់ដើម បណ្តឹងរដ្ឋប្បវេណីថាខ្លួនអាចដោះស្រាយ និងចាប់ខ្លួនឈ្មោះ [redacted] REN GUI ដោយឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំណាយប្រាក់ចំនួន ៣0.000$ (បីម៉ឺន)ដុល្លារអាមេរិក ។ ដោយមានការទុកចិត្ត នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២0២១ ឈ្មោះ [redacted] តាយស៊ីង បានឲ្យបុគ្គលិក ឈ្មោះ [redacted] សុភ័ក្រ ដែលមានគណនីលេខ 000៣២៤៦៨២ ទៅដាក់ប្រាក់ចំនួន ៣0.000$ (បីម៉ឺនដុល្លារអាមេរិក) ទៅកាន់គណនីលេខ 000៣៣៦៦៨0 របស់ឈ្មោះ [redacted] កុសល (SOK KOSAL) តាមរយៈប័ណ្ណដាក់ប្រាក់លេខ FJB2117228242778 របស់ធនាគារវឌ្ឍន:អាស៊ីចំកាត់ (ABA) ។ ក្រោយពីឈ្មោះ [redacted] កុសល ទទួលបានប្រាក់រួចរាល់ហើយ បែរជាមិនធ្វើដូចការអះអាងខាងលើ ហើយធ្វើការគេចវេសមិនព្រមដោះស្រាយនោះទេ ។

-បានឃើញ ពាក្យពីងពាក់និងផ្ទេរសិទ្ធិជូនមេធាវីរបស់ឈ្មោះ [redacted] សាក់ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២0២១ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២0២១ របស់លោកមេធាវី [redacted] លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១១៧៧ អ.ឃ.ក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២0២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៣៩៨0 អ.ឃ.ក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២0២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៥១0 "ច" ដ.ដ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២0២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ខ្លួនស្គាល់ឈ្មោះ [redacted] នៅអំឡុងខែឧសភា ឆ្នាំ២0២១ ពេលខ្លួនទៅសាលាដំបូងខេត្តព្រះសីហនុ ដើម្បីបកប្រែឲ្យចៅកែក្រុមហ៊ុនហាងបញ្ចាំគីម គីម ឯ.ក ជាជនជាតិចិន ដែលទៅដាក់ពាក្យបណ្តឹងប្តឹងជនជាតិចិន ឈ្មោះ [redacted] REN GUI ដែលបានលួចសម្ភារៈរបស់ក្រុមហ៊ុន ដោយទៅជាមួយឈ្មោះ [redacted] សាក់ និងចៅកែក្រុមហ៊ុន ឈ្មោះ [redacted] តាយស៊ីង ។ ស្រាប់តែឈ្មោះ [redacted] កុសល បានដើរមករកពួកខ្លួន រួចនិយាយថា ខ្លួនអាចដោះស្រាយនាំឈ្មោះ [redacted] REN GUI មកទទួលខុសត្រូវចំពោះករណីរបស់ពួកខ្លួនបាន រួចខ្លួនបានឲ្យលេខទូរស័ព្ទទៅឈ្មោះ [redacted] កុសល ដើម្បីទាក់ទងគ្នា ។ បន្ទាប់ពីនេះ0២ ថ្ងៃ ឈ្មោះ [redacted] កុសល បានទូរស័ព្ទមកខ្លួនសុំណាត់ជួបចរចារសេវារត់ការ ខ្លួនក៏បានទៅសួរចៅកែររបស់ខ្លួន គាត់ក៏យល់ព្រមឲ្យខ្លួនទៅជួប ។ ខ្លួនក៏បានទៅជួបឈ្មោះ [redacted] កុសល នៅតុលាការខេត្តព្រះសីហនុ ពេលទៅដល់គាត់បានសួរខ្លួនថា តើចៅកែមានលុយឬអត់? ខ្លួនឆ្លើយថា គាត់មានលុយឬអត់ តើសួរធ្វើអី? និយាយតែរឿងត្រូវចរចារមកថាអស់ប៉ុន្មាន ? រួចឈ្មោះ [redacted] កុសល បានទាមទារថ្លៃសេវា ចំនួន ៥0.000 (ប្រាំម៉ឺន) ដុល្លារអាមេរិក ខ្លួនក៏បានទាក់ទងទៅចៅកែរបស់ខ្លួន គាត់ទាមទារឲ្យចុះបន្តិច ឈ្មោះ [redacted] កុសល បានបញ្ចុះមកនៅត្រឹម ៤0.000 (បួនម៉ឺន) ដុល្លាររអាមេរិក ប៉ុន្តែចៅកែរបស់ខ្លួននៅតែមិនព្រមក្រោយមកក៏ចុះមកនៅត្រឹម ៣0.000(បីម៉ឺន)ដុល្លារអាមេរិក រួចក៏ព្រមព្រៀងគ្នា ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២0២១ ចៅកែរបស់ខ្លួនបានឲ្យខ្លួនទៅវេរប្រាក់តាមធនាគារABA ទៅគណនីលេខ 000៣៣៦៦៨0 របស់ឈ្មោះ [redacted] កុសល តាមរយៈ

ប័ណ្ណដាក់ប្រាក់លេខ FJB2117228242778 ដោយទឹកប្រាក់នោះជារបស់ក្រុមហ៊ុន ។ បន្ទាប់មកឈ្មោះ [redacted] កុសល បានប្រាប់មកខ្លួនវិញតាមរយៈតេលេក្រាមលេខ ០៧០ ៨៨ ២៣ ៨៣ ថាបានទទួលប្រាក់រួចហើយ ។ ក្រោយពីថ្ងៃទទួលប្រាក់មក ពេលខ្លួនតេរសួរនាំ គាត់តែងតែពន្យាពេលយកលេសនេះនោះ រួចប្រាប់ថាខាងឈ្មោះ [redacted] REN GUI មានអ្នកនៅពី ក្រោយដោយគេដាក់លុយ ២០ ម៉ឺនដុល្លារអាមេរិក ឮដូចនេះ ខ្លួនក៏ប្រាប់ទៅឈ្មោះ [redacted] កុសល វិញថា បើដូចនេះឲ្យប្រាក់ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក មកខ្លួនវិញមកខ្លួនមិនធ្វើអ្វីទៀតទេ ។ គាត់ក៏បានឆ្លើយតបមកវិញថា មិនអីទេ គេគ្រាន់តែពញ្ជាក់អារម្មណ៍យើង កុំឲ្យខ្លួនបារម្ភអីខ្លួនបានសួរគាត់ថា តើមួយសប្តាហ៍បានទេ គាត់បានឆ្លើយយល់ព្រម ។ ប៉ុន្តែដល់ពេលសន្យា គាត់សុំពន្យាពេលរហូត ពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ទៅមួយខែ ។ រួចគាត់បានលុបសារក្នុងតេលេក្រាមរវាងខ្លួននិងគាត់ ។ ចាប់តាំងពីពេលគាត់ទទួលប្រាក់លទ្ធផលដែលទទួលបាន មានតែដីកាកោះហៅ ដោយពួកខ្លួនបានចូលឆ្លើយតាមដីកាកោះប៉ុន្តែឈ្មោះ [redacted] REN GUI មិនបានចូលទេ ខ្លួនក៏បានសួរទៅឈ្មោះ [redacted] កុសល តែគាត់ចេះតែឲ្យចាំ ។ ខ្លួនក៏ប្រាប់ទៅគាត់ថាខ្លួនឈប់ធ្វើហើយរួចទារប្រាក់ខ្លួនមកវិញ ។ ដល់ថ្ងៃច័ន្ទ ដែលបានសន្យាមកដល់ ខ្លួនក៏ទាក់ទងគាត់មិនបាន ។ លុះពីរថ្ងៃក្រោយមកគាត់បានទាក់ទងមកខ្លួនរួចប្រាប់ថាគាត់រវល់បុណ្យនៅផ្ទះរហូតដល់ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២២ គាត់បានផ្ញើរសារមកខ្លួនថា (ចាំទំនេរ ជួបគ្នា) តាំងពីថ្ងៃនោះ ខ្លួនមិនអាចទាក់ទងគាត់បានទៀតទេ ដោយគាត់បាន BLOCK លេខទូរស័ព្ទនិងតេលេក្រាមរបស់ខ្លួនទាំងអស់ ។ ខ្លួនមានទំនុកចិត្តពីងពាក់ឲ្យគាត់ជួយដោយគិតថា គាត់ជាមន្ត្រីនៅតុលាការ ព្រោះឃើញស្លៀកពាក់ស្អាតបាតមានកាតព្រឹមត្រូវ ដោយពុំដឹងគាត់មានតួនាទីជាអ្វីឡើយ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] កុសល នៅចៅក្រមស៊ើបសួរបានឆ្លើយថា៖ ខ្លួនបានស្គាល់ឈ្មោះ [redacted] សុភ័ក្រ ក្នុងអំឡុងឆ្នាំ២០២១ ដោយសារមកដាក់ពាក្យបណ្តឹងនៅតុលាការខេត្តព្រះសីហនុ រួចឈ្មោះ [redacted] សុភ័ក្រ បានបបួលខ្លួនជជែកគ្នា និងបានណាត់ជួបគ្នានៅហាងកាហ្វេ ហើយបានសួរនាំខ្លួនរឿងទិញលក់ ជួល ដី ដោយគាត់ប្រាប់ខ្លួនថា គាត់ចង់ទិញដីមានថៅកែចិននៅពីក្រោយ ។ បន្ទាប់មកឈ្មោះ [redacted] សុភ័ក្រ បានទាក់ទងឲ្យខ្លួនជួយដើររកទិញដីឲ្យដោយមិនកំណត់ទំហំ ក្នុងគោលបំណងយកលក់ចំណេញ ខ្លួនបានប្រាប់ថាមិនអាចរកទិញដីបានទេបើគ្មានលុយ ក្រោយមកឈ្មោះ [redacted] សុភ័ក្រ បានវេរលុយឲ្យខ្លួនចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តាមរយៈគណនីរបស់ខ្លួនលេខ ០០០៣៣៦៦៨០ របស់ធានាគារវឌ្ឍនៈ ចំណែកគណនីឈ្មោះ [redacted] សុភ័ក្រ ខ្លួនពុំចាំទេ ដើម្បីស្វែងរកទិញដី ។ ចំពោះការរកទិញដី ខ្លួនបានរកទិញនៅខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកែប នៅពេលដែលខ្លួនដើរមកមើលឃើញទីតាំងដីរួចហើយ បានជូនដំណឹងទៅឈ្មោះ [redacted] សុភ័ក្រ តាមរយៈតេលេក្រាមដែលមានការថតជាវីឌីអូ បង្ហាញទីតាំងដីទៅឲ្យឈ្មោះ [redacted] សុភ័ក្រ បានដឹងនិងបានឃើញ ដើម្បីទំនាក់ទំនងទិញ តែឈ្មោះ [redacted] សុភ័ក្រ បានប្រាប់ថានិងទំនាក់ទំនងទៅថៅកែចិននិងផ្តល់ព័ត៌មានតាមក្រោយថាត្រូវទិញ ឬមិនទិញតែជាក់ស្តែងមិនបានទិញនិងមិនបានឆ្លើយតបទេ ។ ខ្លួនបានចំណាយពេលរកទីតាំងដី ទីតាំងអគារ ដើម្បីជូនដំណឹងទៅឲ្យឈ្មោះ [redacted] សុភ័ក្រ ដើម្បីទំនាក់ទំនងទិញអចលនទ្រព្យទាំងនោះគ្រប់ទីកន្លែង ប៉ុន្តែគាត់ពុំបានទិញដី ដែលខ្លួនបានផ្តល់ព័ត៌មានទៅឲ្យគាត់នោះទេ ។ នៅចុងឆ្នាំ ២០២១ ឈ្មោះ [redacted] សុភ័ក្រ បានទាក់ទងមកខ្លួនដើម្បីទារប្រាក់ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក នោះវិញ ខ្លួនយល់ព្រមឲ្យគាត់ ៥០ % វិញ ពីព្រោះប្រាក់នោះ ខ្លួនបានយកប្រើប្រាស់ធ្វើសាហ៊ុយពេលដើរទិញដីអស់ហើយ

ប៉ុន្តែឈ្មោះ [redacted] សុភ័ក្រ មិនព្រម ។ ក្រោយមកខ្លួនបានទទួលដំណឹងថាឈ្មោះ [redacted]សាក់ បានដាក់ពាក្យបណ្តឹងប្តឹងខ្លួនរឿងប្រាក់ ចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក ។ ខ្លួនសំនូមពរលើកលែងការចោទប្រកាន់។

-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ជាមេធាវីការពារក្តីនិងតំណាងឲ្យអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាក់ បានឆ្លើយថា៖ កាលពីអំឡុងខែមីនា ឆ្នាំ២០២១ កូនក្តីខ្លួនឈ្មោះ [redacted]សាក់ តំណាងឲ្យក្រុមហ៊ុនហាង [redacted]មគីម ឯ.ក បានទៅដាក់ពាក្យបណ្តឹងប្តឹងទៅលើបុគ្គលិករបស់គាត់ ដែលបានលួចទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនហើយ មកសាលាដំបូងខេត្តព្រះសីហនុ បន្ទាប់មកក៏បានជួបនឹងឈ្មោះ [redacted] កុសល ដោយឈ្មោះនេះបានអះអាងថា ខ្លួនជាមេធាវីអាចដោះស្រាយ និងចាប់ខ្លួនបុគ្គលិកឈ្មោះ [redacted] REN GUI បានក្នុងរយៈពេល០១ខែ ទើបកូនក្តីខ្លួនសម្រេចចិត្តពឹងពាក់ឈ្មោះ [redacted] កុសល ហើយឈ្មោះ [redacted] កុសល បានទាមទារថ្លៃ សេវាមេធាវីចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក ពីកូនក្តីដើម្បីដំណើរការនីតិវិធី ។ បន្ទាប់ពីការព្រមព្រៀងគ្នា នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ កូនក្តីខ្លួនបានឲ្យបុគ្គលិកឈ្មោះ PHEARK ដែលមានគណនីលេខ 000៣២៤៦៨២ ទៅដាក់ប្រាក់ឲ្យឈ្មោះ [redacted] កុសល [redacted] KOSAL) ចំនួន ៣0.000(បីម៉ឺន) ដុល្លារអាមេរិក ទៅកាន់គណនីលេខ 000៣ ៣៦៦៨0 តាមប័ណ្ណដាក់ប្រាក់លេខ FJB ២១១៧២២៨២៤២៧៧៨ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ។ ក្រោយពីឈ្មោះ [redacted] កុសល បានទទួលប្រាក់ហើយបែរជាមិនធ្វើបានដូចការអះអាងខាងលើកូនក្តីរបស់ខ្លួនបានស្រាវ ជ្រាវទៅដឹងថា បុគ្គលឈ្មោះ [redacted] កុសល នេះមិនមែនជាមេធាវីនោះទេ ។ សូមបញ្ជាក់ថា នៅថ្ងៃដែលឈ្មោះ [redacted] កុសល បានអះអាងថាខ្លួនជាមេធាវី និងទាមទារប្រាក់ក្នុងការដោះស្រាយ និងចាប់ខ្លួននោះគឺកូនក្តីខ្លួនឈ្មោះ [redacted]សាក់ បានទៅជាមួយឈ្មោះ [redacted] សុភ័ក្រ ដែរជាអ្នកដឹងឮពីរឿងនេះ ។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានសន្និដ្ឋានថា: ឆ្លងតាមរយៈសន្និដ្ឋានស្តាពររបស់តំណាងអយ្យការ និងដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ឃើញថាជនជាប់ចោទឈ្មោះ [redacted] កុសល ពិតជាបានឆបោកប្រាក់កូនក្តីខ្លួនចំនួន ៣0,000 (បីម៉ឺន) ដុល្លារអាមេរិកប្រាកដមែន ពុំមានពាក់ព័ន្ធនឹងការរកទិញដីឡើយ ខ្លួនសំនូមពរ សុំលោកចៅក្រមមេត្តាផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ សុំចេញដីកាចាប់ខ្លួន និងសុំទាមទារសំណងដូចកូនក្តីខ្លួន។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានសន្និដ្ឋានថា: ចំពោះប្រាក់ចំនួន ៣0,000(បីម៉ឺន) ដុល្លារអាមេរិក ជនជាប់ចោទទទួលស្គាល់ថា បានទទួលមែន តែបង្ហែរថាជាលុយទិញដី តាមសាក្សីបានបញ្ជាក់ថា ក្រុមហ៊ុនមិនដែលមានប្រវត្តិទិញដីទេ ហើយបើចង់ទិញដីមិនចាំបាច់មកតុលាការដែរ ។ ឈ្មោះ [redacted] កុសល មានគំនិតទុច្ចរិត ស្មើសុំលោកចៅក្រម មេត្តាចេញដីកាចាប់ខ្លួនជនជាប់ចោទ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] កុសល ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ **ឆបោក** ប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពី២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] កុសល បានសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលរួចមក ឃើញថា កូនក្តីខ្លួនបានសារភាពថា គាត់បានទទួលប្រាក់ ចំនួន ៣0,000(បីម៉ឺន) ដុល្លារអាមេរិក មែន ដើម្បីចំណាយធ្វើសោហ៊ុយសម្រាប់រកទិញដីឲ្យដើមចោទ ហើយគាត់

ទីឯសងប្រាក់នេះឲ្យដើមបណ្តឹង ។ រឿងក្តីនេះ ជារឿងរដ្ឋប្បវេណី តាមបញ្ញាតិមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំលោកចៅក្រមសម្រេចឲ្យក្លូនក្តីខ្លួនរួចផុតបទចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាដំបូងរាជធានីភ្នំពេញ</u>

<u>យល់ឃើញថា</u>

១-នៅអំឡុងខែមីនា ឆ្នាំ២០២១ នៅក្រុងព្រះសីហនុ ឈ្មោះ [redacted] **សាក់** បានផ្ទេរការងារមកឲ្យឈ្មោះ **ចុង តាយស៊ីង** ដែលមានអ្នកបកប្រែ ឈ្មោះ [redacted] **សុភ័ក្រ** ក្នុងការដាក់ពាក្យបណ្តឹងទៅលើឈ្មោះ[redacted] REN GUI នៅសាលាដំបូងខេត្តព្រះសីហនុ ក៏បានជួបជាមួយឈ្មោះ [redacted] **កុសល** ហើយឈ្មោះនេះបានធានាអះអាងប្រាប់ថា ខ្លួនអាចដោះស្រាយ និងចាប់ខ្លួន ឈ្មោះ [redacted] REN GUI បានដោយមានការទុកចិត្តលើ ឈ្មោះ [redacted] **តាយស៊ីង** បានឲ្យបុគ្គលិកឈ្មោះ [redacted] **សុភ័ក្រ** ធ្វើការដាក់ប្រាក់ទៅឲ្យឈ្មោះ [redacted] **កុសល** ចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក ក្រោយពីទទួលបានប្រាក់រួចរាល់ហើយ ឈ្មោះ [redacted] **កុសល** បែរជាមិនធ្វើដូចការអះអាងខាងលើ ហើយធ្វើការគេចវេសមិនព្រមដោះស្រាយនោះទេ ។

២-តាមអំណានចម្លើយជនជាប់ចោទ ឈ្មោះ [redacted] **កុសល** បានឆ្លើយថា៖ ខ្លួនបានស្គាល់ឈ្មោះ [redacted] **សុភ័ក្រ** ក្នុងអំឡុងឆ្នាំ២០២១ ដោយសារមកដាក់ពាក្យបណ្តឹងនៅតុលាការខេត្តព្រះសីហនុ ហើយឈ្មោះ [redacted] **សុភ័ក្រ** បានណាត់ជួបគ្នានៅហាងកាហ្វេ ហើយបានសួរនាំខ្លួនរឿងទិញលក់ ជួល ដី ដោយគាត់ប្រាប់ខ្លួនថាគាត់ចង់ទិញដីមានថៅកែចិននៅពីក្រោយ ។ បន្ទាប់មកឈ្មោះ [redacted] **សុភ័ក្រ** បានទាក់ទងឲ្យខ្លួនជួយដើររកទិញដីឲ្យដោយមិនកំណត់ទំហំ ក្នុងគោលបំណងយកលក់ចំណេញ ខ្លួនបានប្រាប់ថាមិនអាចរកទិញដីបានទេបើគ្មានលុយ ក្រោយមកឈ្មោះ [redacted] **សុភ័ក្រ** បានវេរលុយឲ្យខ្លួនចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក តាមរយៈគណនីរបស់ខ្លួនលេខ 000៣៣៦៦៨0 របស់ធានាគារវឌ្ឍនៈ ចំណែកគណនីឈ្មោះ [redacted] **សុភ័ក្រ** ខ្លួនពុំចាំទេដើម្បីស្វែងរកទិញដី ។ ចំពោះការរកទិញដី ខ្លួនបានរកទិញនៅខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកែប នៅពេលដែលខ្លួនដើរមកមើលឃើញទីតាំងដីរួចហើយ បានជូនដំណឹងទៅឈ្មោះ [redacted] **សុភ័ក្រ** តាមរយៈតេលេក្រាមដែលមានការថតជាវីឌីអូ បង្ហាញទីតាំងដីទៅឲ្យឈ្មោះ [redacted] **សុភ័ក្រ** បានដឹងនិងបានឃើញដើម្បីទំនាក់ទំនងទិញ តែឈ្មោះ [redacted] **សុភ័ក្រ** បានប្រាប់ថានិងទំនាក់ទំនងទៅថៅកែចិន និងផ្តល់ព័ត៌មានតាមក្រោយថាត្រូវទិញ ឬមិនទិញតែជាក់ស្តែងមិនបានទិញនិងមិនបានឆ្លើយតបទេ ។ ខ្លួនបានចំណាយពេលរកទីតាំងដីទីតាំងអគារ ដើម្បីជូនដំណឹងទៅឲ្យឈ្មោះ [redacted] **សុភ័ក្រ** ដើម្បីទំនាក់ទំនងទិញដីទាំងនោះគ្រប់ទីកន្លែង ប៉ុន្តែគាត់ពុំបានទិញដីទេ ។ នៅចុងឆ្នាំ២០២១ ឈ្មោះ [redacted] **សុភ័ក្រ** បានទាក់ទងមកខ្លួនដើម្បីទារប្រាក់ ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក នោះវិញ ខ្លួនយល់ព្រមឲ្យគាត់ ៥0 % វិញ ពីព្រោះប្រាក់នោះ ខ្លួនបានយកប្រើប្រាស់ធ្វើ

សាហ៊ុយពេលដើរទិញដីអស់ហើយ ប៉ុន្តែឈ្មោះ [redacted] សុភ័ក្រ មិនព្រម ។ ក្រោយមកខ្លួនបានទទួលដំណឹងថា ឈ្មោះ [redacted] សាក់ បានដាក់ពាក្យបណ្តឹងប្តឹងខ្លួនរឿងប្រាក់ ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

៣-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ចន្ត្រា និងឈ្មោះ [redacted] ហ៊ួ ជាមេធាវីការពារការពារសិទ្ធិ ឲ្យដើមបណ្តឹងឈ្មោះ [redacted] សាក់ បានឆ្លើយថា៖ កាលពីអំឡុងខែមីនា ឆ្នាំ២០២១ កូនក្តីខ្លួនឈ្មោះ [redacted] សាក់ តំណាងឲ្យក្រុមហ៊ុនហាង បញ្ចាំ គីមគីម ឯ.ក បានទៅដាក់ពាក្យបណ្តឹងប្តឹងទៅលើបុគ្គលិករបស់គាត់ ដែលបានលួចទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនហើយ មកសាលាដំបូងខេត្តព្រះសីហនុ បន្ទាប់មកក៏បានជួប នឹង ឈ្មោះ [redacted] កុសល ដោយឈ្មោះនេះបានអះអាងថា ខ្លួនជាមេធាវីអាចដោះស្រាយ និងចាប់ខ្លួនបុគ្គលិកឈ្មោះ WANG REN GUI បានក្នុងរយៈពេល០១ខែ ទើបកូនក្តីខ្លួនសម្រេចចិត្តពឹងពាក់ឈ្មោះ [redacted] កុសល ហើយឈ្មោះ សុខ កុសល បានទាមទារថ្លៃសេវាមេធាវីចំនួន៣០.០០០(បីម៉ឺន)ដុល្លារអាមេរិក ពីកូនក្តីដើម្បីដំណើរការនីតិវិធី ។ បន្ទាប់ពីការព្រមព្រៀងគ្នា នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ កូនក្តីបានឲ្យបុគ្គលិកឈ្មោះ PHEARK ដែលមានគណនីលេខ ០០០៣២៤៦៨២ ទៅដាក់ប្រាក់ឲ្យឈ្មោះ [redacted] កុសល [redacted] KOSAL) ចំនួន ៣០.០០០(បីម៉ឺន) ដុល្លារអាមេរិក ទៅកាន់គណនីលេខ ០០០៣ ៣៦៦៨០ តាមប័ណ្ណដាក់ប្រាក់លេខ FJB២១១៧២២៨២៤២៧៧៨ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ។ ក្រោយពីឈ្មោះ [redacted] កុសល បានទទួលប្រាក់ហើយបែរជាមិនធ្វើបានកូនក្តីរបស់ខ្លួនបានស្រាវជ្រាវទៅដឹងថា បុគ្គលឈ្មោះ [redacted] កុសល នេះមិនមែនជាមេធាវី នោះទេ ។ សូមបញ្ជាក់ថា នៅថ្ងៃដែលឈ្មោះ [redacted] កុសល បានអះអាងថាខ្លួនជាមេធាវី និងទាមទារប្រាក់ក្នុងការដោះស្រាយ និងចាប់ខ្លួន នោះគឺកូនក្តីខ្លួន ឈ្មោះ [redacted] សាក់ បានទៅជាមួយឈ្មោះ [redacted] សុភ័ក្រ ដែរជាអ្នកដឹងឮពីរឿងនេះ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] កុសល នៅអំឡុងខែឧសភា ឆ្នាំ២០២១ ខ្លួនទៅសាលាដំបូងខេត្តព្រះសីហនុ ដើម្បីបកប្រែឲ្យថៅកែក្រុមហ៊ុនហាងបញ្ចាំគីម គីម ឯ.ក ជាជនជាតិចិន ដែលទៅដាក់ពាក្យបណ្តឹងប្តឹងជនជាតិចិនឈ្មោះ [redacted] REN GUI ដែលបានលួចសម្ភារៈរបស់ក្រុមហ៊ុន ជាមួយឈ្មោះ [redacted] សាក់ និងថៅកែក្រុមហ៊ុនឈ្មោះ [redacted] តាយស៊ីង ស្រាប់តែឈ្មោះ [redacted] កុសល បានដើរមករកពួកខ្លួន រួចនិយាយថា គាត់អាចដោះស្រាយនាំឈ្មោះ [redacted] REN GUI មកទទួលខុសត្រូវចំពោះករណីរបស់ពួកខ្លួនបាន រួចខ្លួនបានឲ្យលេខទូរស័ព្ទទៅឈ្មោះ [redacted] កុសល ដើម្បីទាក់ទងគ្នា ។ បន្ទាប់ពីនេះ០២ថ្ងៃ ឈ្មោះ [redacted] កុសល បានទូរស័ព្ទមកខ្លួនសុំណាត់ជួបចរចារសេវារត់ការ ខ្លួនក៏បានទៅសួរថៅកែរបស់ខ្លួន គាត់ក៏យល់ព្រមឲ្យខ្លួនទៅជួប ។ ខ្លួនក៏បានទៅជួបឈ្មោះ [redacted] កុសល នៅតុលាការខេត្តព្រះសីហនុ ពេលទៅដល់គាត់បានសួរខ្លួនថា តើថៅកែមានលុយឬអត់? ខ្លួនឆ្លើយថា គាត់មានលុយឬអត់ តើសួរធ្វើអី? និយាយតែរឿងត្រូវចរចារមកថាអស់ប៉ុន្មាន ? រួចឈ្មោះ [redacted] កុសល បានទាមទារថ្លៃសេវា ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ខ្លួនក៏បានទាក់ទងទៅថៅកែរបស់ខ្លួន គាត់ទាមទារឲ្យចុះបន្តិច ឈ្មោះ [redacted] កុសល បានបញ្ចុះមកនៅត្រឹម ៤០.០០០ (បួនម៉ឺន) ដុល្លាររអាមេរិក ប៉ុន្តែថៅកែរបស់ខ្លួននៅតែមិនព្រមក្រោយមកក៏ចុះមកនៅត្រឹម ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក រួចក៏ព្រមព្រៀងគ្នា ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ថៅកែរបស់ខ្លួនបានឲ្យខ្លួនទៅអេរប្រាក់តាមធនាគារABA ទៅគណនីលេខ ០០០៣៣ ៦៦៨០ របស់ឈ្មោះ [redacted] កុសល តាមរយៈប័ណ្ណដាក់ប្រាក់លេខ FJB2117228242778 ដោយទឹកប្រាក់នោះជារបស់ក្រុមហ៊ុន ។ បន្ទាប់មកឈ្មោះ [redacted] កុសល បានប្រាប់មកខ្លួនវិញតាមរយៈតេលេក្រាមលេខ ០៧០ ៨៨ ២៣ ៨៣ ថាបានទទួលប្រាក់រួចហើយ ។ ក្រោយពីថ្ងៃទទួលប្រាក់មក ពេលខ្លួនតេរសួរនាំ គាត់តែងតែពន្យាពេលយកលេសនេះនោះ រួចប្រាប់ថាខាងឈ្មោះ

[redacted]REN GUI មានអ្នកនៅពី ក្រោយដោយគេដាក់លុយ ២០ ម៉ឺន ដុល្លារអាមេរិក ឮដូចនេះ ខ្លួនក៏ប្រាប់ទៅឈ្មោះ [redacted] កុសល វិញថា បើដូចនេះឲ្យប្រាក់ ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក មកខ្លួនវិញមកខ្លួនមិនធ្វើអ្វីទៀតទេ ។ គាត់ក៏បានឆ្លើយតបមកវិញថា មិនអីទេ គេគ្រាន់តែពញ្ជាក់អារម្មណ៍យើង កុំឲ្យខ្លួនបារម្ភអីខ្លួនបានសួរគាត់ថា តើមួយសប្តាហ៍បានទេ គាត់បានឆ្លើយយល់ព្រម ។ ប៉ុន្តែដល់ពេលសន្យា គាត់សុំពន្យាពេលរហូត ពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ទៅមួយខែ ។ រួចគាត់បានលុបសារក្នុងតេលេក្រាមរវាងខ្លួននិងគាត់ ។ ចាប់តាំងពីពេលគាត់ទទួលប្រាក់លទ្ធផលដែលទទួលបាន មានតែដីកាកោះហៅ ដោយពួកខ្លួនបានចូលឆ្លើយតាមដីកាកោះ ប៉ុន្តែឈ្មោះ [redacted] REN GUI មិនបានចូលទេ ខ្លួនក៏បានសួរទៅឈ្មោះ [redacted] កុសល តែគាត់ចេះតែឲ្យចាំ ។ ខ្លួនក៏ប្រាប់ទៅគាត់ថាខ្លួនឈប់ធ្វើហើយរួចទារប្រាក់ខ្លួនមកវិញ ។ ដល់ថ្ងៃច័ន្ទ ដែលបានសន្យាមកដល់ ខ្លួនក៏ទាក់ទងគាត់មិនបាន ។ លុះពីរថ្ងៃក្រោយមកគាត់បានទាក់ទងមកខ្លួនរួចប្រាប់ថាគាត់រវល់បុណ្យនៅផ្ទះរហូតដល់ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ គាត់បានផ្ញើរសារមកខ្លួនថា (ចាំទំនេរ ជួបគ្នា) តាំងពីថ្ងៃនោះ ខ្លួនមិនអាចទាក់ទងគាត់បានទៀតទេ ដោយគាត់បាន BLOCK លេខទូរស័ព្ទនិងតេលេក្រាមរបស់ខ្លួនទាំងអស់ ។

៥-តាចម្លើយជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយថា ខ្លួនបានទទួលប្រាក់ចំនួន ៣0,000(បីម៉ឺន) ដុល្លារអាមេរិក ពីឈ្មោះ [redacted] សុភ័ក្រ ប្រាកដមែន គឺសម្រាប់ចំណាយក្នុងការធ្វើហ៊ុយស្វែងរកទិញដីឲ្យដើមចោទតែជនជាប់ចោទពុំមានភស្តុតាងជា ឯកសារ ឬសាក្សីណាម្នាក់មកឆ្លើយដោះបន្ទុកឲ្យខ្លួនឡើយ ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] កុសល គ្រាន់តែជាចម្លើយដោះសារ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌតែប៉ុណ្ណោះ។

៦-តាមចម្លើយមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងឈ្មោះ [redacted] សាក់ និងចម្លើយសាក្សីឈ្មោះ [redacted] សុភ័ក្រ មានភាពស៊ីសង្វាក់គ្នា ដែលបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] **កុសល** ពិតជាបានទទួល ប្រាក់ពីដើមបណ្តឹងដើម្បីរត់ការ ប៉ុន្តែបន្ទាប់ពីទទួលបានប្រាក់ហើយជនជាប់ចោទយកទៅចាយវាយផ្ទាល់ខ្លួន និងគេចវេសពីការទទួលខុសត្រូវ ដែលនេះអាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រើឧបាយកលទុច្ចរិត ដើម្បីឲ្យជនរងគ្រោះប្រគល់ប្រាក់ឲ្យខ្លួន ហើយយកទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ប្រាកដមែន ដែលអំពើនេះ គឺជាបទល្មើសព្រហ្មទណ្ឌក្នុងបទ **ឆបោក** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] កុសល ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជន នេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន ចំពោះមុខច្បាប់ព្រហ្មទណ្ឌ ជាធរមាន។

៨-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] កុសល ភេទប្រុស **អាយុ២៩ឆ្នាំ** ពីបទ **ឆបោក** ប្រព្រឹត្តនៅខេត្តព្រះសីហនុ កាលពីឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៩-ជនជាប់ចោទឈ្មោះ [redacted] កុសល តាមជីវប្រវត្តរបស់គេកន្លងមក ពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១0-ក្នុងរឿងនេះ ឈ្មោះ [redacted] សាក់ ជាតំណាងឱ្យក្រុមហ៊ុន ហាងបញ្ចាំគីម គីម ឯ.ក បានប្តឹងទាមទារសំណង ចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក និងទាមទារសំណងជម្ងឺចិត្ត និងសោរាមេធាវី ចំនួន ៥0.000 (ប្រាំម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១១-ព្យសនកម្ម ដែលកើតឡើងលើដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សាក់ ដែលបាត់បង់ទ្រព្យសម្បត្តិ និងខាតបង់ពេលវេលាដោយសារអំពើទុច្ចរិតរបស់ជនជាប់ចោទឈ្មោះ [redacted]កុសល ដូច្នេះ ជនជាប់ចោទរូបនេះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះសំណងការខូចខាត និងសំណងជំងឺចិត្ត តាមកំរិត និងព្យសនកម្ម ដែលកើតឡើងចំពោះជនរងគ្រោះ។

១២-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី អាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៣-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់អាចឱ្យតុលាការ លើកយកការសន្និដ្ឋានរបស់តំណាងអយ្យការ មកពិចារណាក្នុងការសម្រេចសេចក្តី។

១៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ពុំមានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តីបានឡើយ។

ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted]កុសល ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះ ត្រូវព្យួរធម្មតាតាមបញ្ញត្តិមាត្រា ១០៦ ,មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន) រៀល ។

ពីបទ **រឺបោក** ប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីឆ្នាំ២០២១ បទល្មើស ព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យឈ្មោះ [redacted] **កុសល** សងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក និងជម្ងឺចិត្ត ចំនួន ២,០០០,០០០ (ពីរលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **សាក់** ។ ការទាមទារលើសពីនេះ សម្រេចច្រានចោល។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] កុសល និងចាត់ទុកជាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាក់** និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ។ ភាគីមានសិទ្ធិទាស់ ឬប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ក្រឡាបញ្ជីសង្ឃនាការ

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ១២ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]